# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣១ ... សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីទទួលបន្ទុកការរៀបចំព្រឹត្តិការណ៍ "ការប្រកួតកីឡាវាយកូនហ្គោល អាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodian Open 2008 " នៅខេត្តសៀមរាប ពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួទេសចរណ៍

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីរៀបចំព្រឹត្តិការណ៍ **"ការប្រកួតកីឡាវាយកូនគោល អាស៊ី លក្ខណៈអន្តរជាតិ** Johnnie Walker Cambodian Open 2008" **ពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៨ នៅខេត្តសៀមរាប** រួមមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | ប្រធាន |
| ២- ឯកឧត្តម | **អ៊ុក ប្រាជ្ញា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | អនុប្រធាន |
| ៣- ឯកឧត្តម | **សូ ម៉ារ៉ា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្តម | **លឹម ស៊ីដេនីន** | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |

៥- ឯកឧត្តម ស៊ូ ភិរិន្ទ អភិបាលខេត្តសៀមរាប អនុប្រធាន
៦- ឯកឧត្តម មាស សារិន អនុរដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា និងជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អនុប្រធាន
៧- ឯកឧត្តម ហោ សារុន អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិកអចិន្ត្រៃយ៍
៨- ឧត្តមសេនីយ៍ ឥត សារ៉ាត់ អគ្គលេខាធិការសហព័ន្ធកីឡាវាយកូនហ្គោលកម្ពុជា សមាជិក
៩- ឯកឧត្តម គីម គុណវឌ្ឍន៍ អគ្គនាយក នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា សមាជិក
១០- ឯកឧត្តម ជា បូរ៉ា អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ សមាជិក
១១- ឯកឧត្តម ម៉ី ម៉ារ៉ានី អគ្គនាយករងអាជ្ញាធរអប្សរា សមាជិក
១២- ឧត្តមសេនីយ៍ ថោង លឹម ប្រធាននាយកដ្ឋានអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ សមាជិក
១៣- ឧត្តមសេនីយ៍ ញាណ ទិមុល ប្រធាននាយកដ្ឋាននគរបាលទេសចរណ៍ នៃក្រសួងមហាផ្ទៃ សមាជិក
១៤- លោក ឡាយ ឫទ្ធី នាយករងទីចាត់គយ និងរដ្ឋាករ សមាជិក
១៥- លោក ភ្មុយ សខ ប្រធានមន្ទីរទេសចរណ៍ ខេត្តសៀមរាប សមាជិក

**ប្រការ២:** ក្រុមការងារទ្រទ្រង់ ដល់ការរៀបចំព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនហ្គោល អាស៊ី លក្ខណៈអន្តរជាតិ Johnnie Walker Cambodia Open 2008 មានមុខងារ និងភារកិច្ចដូចតទៅ :

- រៀបចំបដិសណ្ឋារកិច្ចស្វាគមន៍ ដល់គណៈប្រតិភូ និងក្រុមកីឡាករអន្តរជាតិវាយកូនហ្គោល នៅច្រកទ្វារព្រលានយន្តហោះអន្តរជាតិភ្នំពេញ ព្រលានយន្តហោះអន្តរជាតិ ខេត្តសៀមរាប និងច្រកទ្វារព្រំដែនអន្តរជាតិផ្សេងៗទៀត ទាំងពេលមកដល់ និងពេលនិវត្តន៍វិញ ។
- ជួយសម្រួលបែបបទ នៃការធ្វើដំណើរ និងបែបបទគយ នៅតាមច្រកទ្វារអន្តរជាតិ ជូនគណៈប្រតិភូ និងក្រុមកីឡាករ ។
- ការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈឱ្យបានល្អ នៅក្នុងពេលប្រកួតកីឡាវាយកូនហ្គោលអាស៊ីលក្ខណៈអន្តរជាតិ នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសនៅលើទឹកដី ខេត្តសៀមរាប ។
- ធ្វើការផ្សព្វផ្សាយតាមបណ្តាញព័ត៌មាន ក្នុងប្រទេស និងក្រៅប្រទេស ជាពិសេសតាមវិទ្យុ ទូរទស្សន៍ ដើម្បីឱ្យទេសចរអន្តរជាតិ និងសាធារណជនបានយល់ជ្រួតជ្រាប និងចូលរួម ក្នុងព្រឹត្តិការណ៍ប្រកួតកីឡាវាយកូនហ្គោលនេះ ។
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងផ្នែកឯកជន ព្រមទាំងមានសិទ្ធិស្វែងរក និងទទួលជំនួយ និងការឧបត្ថម្ភនានា ដល់កិច្ចដំណើរការសកម្មភាពនេះ ។
- ជ្រើសរើសអ្នកជំនាញវាយកូនហ្គោល (Professional Golfer) កម្ពុជា ដើម្បីចូលរួម ។
- ធ្វើរបាយការណ៍អំពីលទ្ធផល នៃការរៀបចំ និងកិច្ចដំណើរការ នៃពិធីនេះ ជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ៣:** ក្រុមការងារនេះ មានលេខាធិការដ្ឋានមួយ ជាជំនួយការ ដែលមានទីតាំង នៅទីស្តីការក្រសួងទេសចរណ៍ មានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម ហោ សារុន អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ ប្រធាន
២- លោក ធង់ សូលីដា អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ និងជានាយកខុទ្ទកាល័យរដ្ឋមន្ត្រី អនុប្រធាន
៣- លោកស្រី ចៅស៊ុន ភិរិយា ប្រធាននាយកដ្ឋាន នៃអាជ្ញាធរអប្សរា អនុប្រធាន
៤- លោក ឡាយ ឫទ្ធី នាយករងទីចាត់ការគយ និងរដ្ឋាករ សមាជិកអចិន្ត្រៃយ៍

៥- លោក សុង តុងហាប់ ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងទេសចរណ៍ សមាជិក
៦- លោក និន សិទ្ធីវង្ស អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ លេខាកត់ត្រា
៧- ឧត្តមសេនីយ៍ ពិន ពិសិដ្ឋ អនុប្រធាននាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក
៨- លោក ឈិន ស៊ីផេង អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ ក្រសួងទេសចរណ៍ សមាជិក
៩- លោក សំ វុទ្ធា អនុប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅក្រសួងទេសចរណ៍ សមាជិក
១០- លោក ខូច ម៉ានី អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងទេសចរណ៍ សមាជិក
១១- វរសេនីយ៍ទោ សំ ស៊ីយ៉ាន ប្រធានអង្គភាពនគរបាលទេសចរណ៍ខេត្តសៀមរាប សមាជិក
១២- លោក ម៉ូវ សេងកាក់ អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក
១៣- លោក ម៉ៅ សុផាត ជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក
១៤- លោក ហង្ស សុណ្ណាប់ ជំនួយការឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ សមាជិក
១៥- លោក ខៃ អាទិត្យា ប្រធានការិយាល័យ នៃក្រសួងព័ត៌មាន សមាជិក
១៦- លោក ប៉ែន សុវណ្ណា ប្រធានការិយាល័យ នៃក្រសួងទេសចរណ៍ សមាជិក
១៧- លោក នឹម ឆន ប្រធានការិយាល័យ នៃមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក
១៨- លោក ធន់ ចាន់នី ប្រធានការិយាល័យ នៃមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក
១៩- លោក អ៊ុន សុខតា អនុប្រធានការិយាល័យ នៃមន្ទីរទេសចរណ៍ខេត្តសៀមរាប សមាជិក
២០- លោក លី សុណារ៉េត មន្ត្រីនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ នៃអាជ្ញាធរអប្សរា សមាជិក
២១- លោក ស៊ឹង សុណាត មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ សមាជិក
២២- លោក រស់ សុភារិទ្ធ មន្ត្រីនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ នៃក្រសួងទេសចរណ៍ សមាជិក
២៣- លោក ឆង មុន្នីកា មន្ត្រីនាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍ សមាជិក

**ប្រការ៤:** -ក្រុមការងារនេះមានសិទ្ធិប្រើប្រាស់ត្រា និងថវិកា របស់ក្រសួងទេសចរណ៍ ក្នុងការបំពេញការងារ។
-សមាជិកនៃក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥:** ក្រុមការងារនេះនឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច។

**ប្រការ៦:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីនៃក្រសួង ស្ថាប័ន និងអភិបាលខេត្តសៀមរាប ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ ខាងលើ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ត.៧ ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ៧
- -ឯកសារ-កាលប្បវត្តិ